Fact Sheet - Khmer

# ការគ្រៀវបំពង់ស្បូនមិនអោយមានកូន

## Tubal Sterilisation

### តើអ្វីជាការគ្រៀវបំពង់ស្បូនមិនអោយមានកូន?

ការគ្រៀវបំពង់ស្បូនមិនអោយមានកូនគឺជាការវះកាត់ដៃលស្ត្រីអាចមាន ហេតុនេះពួកគេមិនក្លាយជាមានគត៌។ វាជាទំរង់អចិន្ត្រៃយ៍មួយនៃការមិន អោយមានកូន។

### តើការគ្រៀវបំពង់ស្បូនមិនអោយមានកូនមានដំណើរការយ៉ាងដូចម្តេច?

ការវះកាត់ទប់ឃាំងដៃស្បូនរបស់ស្ត្រី ហេតុនេះហើយមេជីវិតរបស់បុរសមិនអាចធ្វើដំណើរទៅដល់ជួបពងទឹកកាមស្ត្រី (ពង) បាននិងចាប់ផ្តើម ការមានគត៌បានទេ។

### តើវាដំណើរការបានល្អយ៉ាងដូចម្តេច?

ការគ្រៀវបំពង់ស្បូនមិនអោយមានកូនដំណើរការ បានល្អណាស់។ វាមានប្រសិទ្ធិភាពច្រើនជាង 99% ។

### តើមានអ្វីកើតឡើងនៅពេលដែលអ្នកមានការគ្រៀវបំពង់ស្បូនមិនអោយមានកូន?

វិធីសាស្ត្រជាទូទៅបំផុតហៅថាការគ្រៀវឡាប៉ារ៉ូស្កូពិក (Laparoscopic Sterilisation)។ ជាមួយនឹង វិធីសាស្ត្រនេះស្ត្រីជាធម្មតាត្រូវមានការចាក់ថ្នាំជាទូទៅធ្វើអោយស្ពឹក និងត្រូវស្នាក់នៅក្នុងមន្ទីរពេទ្យមួយយប់។ វេជ្ជបណ្ឌិតធ្វើការវះតូចពីរនៅក្នុងពោះ។
បន្ទាប់មកឡាប៉ារ៉ូស្កូប (គឺជាកែវយិតតូចមួយ) ត្រូវដាក់បញ្ចូល ហេតុនេះវេជ្ជបណ្ឌិតអាចមើលឃើញ បំពង់។
បំពង់ត្រូវបានបិទជាមួយខ្ទាស់កឹប រង្វង់កង ឬដោយការកាត់ ឬការចង។ វិធីសាស្ត្រកាន់តែថ្មីមួយទៀតហៅថា Essure®។
ជាមួយនឹងវិធីសាស្ត្រនេះ វត្ថុតូចៗសំរាប់ដាក់បញ្ចូលត្រូវបានដាក់នៅក្នុងដៃស្បូននិមួយៗតាមរយៈទ្វារមាសនិងកស្បូន។ ជាមួយនឹង Essure® គ្មានការវះណាមួយទេ ហើយវាត្រូវបានធ្វើឡើងនៅក្រោមការប្រើថ្នាំស្ពឹក។ វាចំណាយពេលបរហែល 30 នាទី ហើយស្ត្រីជាច្រើនអាចទៅផ្ទះវិញមួយម៉ោងក្រោយមក។




### ការគ្រៀវបំពង់ស្បូនមិនអោយមានកូន

ក្រោយពីមានការប្រើថ្នាំស្ពឹកទូទៅមក អ្នកអាចមានដំណើរចង់ក្អួត (មានអារម្មណ៍ឈឺ) ឬមានភាពនឿយហត់អស់ពេលពីរបីថ្ងៃ។
ក្រោយពីមានឡាប៉ារ៉ូស្កូពី អ្នកអាចមានការឈឺខ្លះនៅក្នុងពោះនិងស្មាររបស់អ្នក។ ជាធម្មតាវាត្រូវការពេលប្រាំពីរថ្ងៃសំរាប់ស្ត្រីដើម្បីមានអារម្មណ៍ល្អឡើងវិញ។ ស្ត្រីទាំងឡាយដែលធ្វើតាមនីតិវិធី Essure® ជាមួយនឹងថ្នាំស្ពឹកជាធម្មតាជាសះស្បើយវិញកាន់តែលឿន។

### តើវានឹងមានប្រសិទ្ធិភាពនៅពេលណា?

វិធីសាស្ត្រឡាប៉ារ៉ូស្កូពិច អ្នកនឹងត្រូវបានការពារមិនអោយមានកូនភ្លាមតែម្តង។ វិធីសាស្ត្រ Essure® ជាធម្មតាប្រើពេលបីខែដើម្បីដំណើរការ ក៏ប៉ុន្តែវាអាចប្រើពេលកាន់តែយូរ។
អ្នកត្រូវប្រើប្រាស់វិធីសាស្ត្រដទៃក្នុងការមិនអោយមានកូន រហូតដល់ការធ្វើតេស្តបង្ហាញថាបំពង់ត្រូវបានទប់បិទពេញលេញ។

### តើមានផលប៉ះពាល់បន្ទាប់បន្សំឬទេ?

ជាមួយនឹងការវះកាត់ណាមួយ អ្នកអាចមានការស្មុគស្មាញ ដូចជាការហូរឈាមនិងការឆ្លងជំងឺ ក៏ប៉ុន្តែការស្មុគស្មាញទាំងនោះមិនកើតមានជាទូទៅទេ។

### តើមានអ្វីកើតឡើង ប្រសិនបើវាមិនដំណើរការ?

ការវះកាត់ប្រហែលពីរ ទៅប្រាំបួននៅក្នុងចំណោមការវះកាត់ចំនួន 1,000 បានបរាជ័យ។ វាអាចកើតឡើងសូម្បីប៉ុន្មានឆ្នាំក្រោយមក។ ប្រសិនបើវា បរាជ័យ វាមានឱកាសកាន់តែច្រើននៃការមានគត៌ការធ្វើជាកស្បូន (នៅខាងក្រៅស្បូន)។

### តើការគ្រៀវបំពង់ស្បូនមិនអោយមានកូនអាចត្រូវប្តូរបញ្រ្ចាសវិញទេ?

ជូនកាលការគ្រៀវឡាប៉ារ៉ូស្កូពិចអាចផ្តល់ផល បញ្រ្ចាសមកវិញ ក៏ប៉ុន្តែទោះបីដូចនោះមានស្ត្រីតែ 50% ប៉ុណ្ណោះដែលក្លាយជាមានគត៌។ វាក៏មាន ហានិភ័យកាន់តែខ្ពស់ផងដែរនៃការមានគត៌តាម កស្បូន។
វិធីសាស្ត្រ Essure® មិនអាចផ្តល់ផល បញ្រ្ចាសមកវិញទេ។
ប្រសិនបើស្ត្រីម្នាក់គិតថាមានឱកាសណាមួយដែលនាងអាចចង់មានកូននៅក្នុងពេលអនាគត នាងមិនត្រូវមានការគ្រៀវបំពង់ស្បូនមិនអោយមានកូន។ វា ល្អបំផុតមិនត្រូវធ្វើសេចក្តីសំរេចធំមួយបែបនេះទេ ប្រសិនបើអ្នកស្ថិតនៅក្រោមភាពតឹងតែង ដូចជាគ្រាន់តែក្រោយពីមានទារក ឬការរលូតកូន ឬ នៅពេលដែលអ្នកមានបញ្ហាដទៃទៀត។


ផែនការគ្រួសារ NSW គឺជាអង្គការមិនរកកម្រៃមួយដែលត្រូវបានផ្តល់មូលនិធិដោយក្រសួងសុខាភិបាល នៃរដ្ឋ NSW

ពត៌មាននៅក្នុងក្រដាសអង្គហេតុនេះត្រូវបានផ្តល់ជូនសំរាប់គោលបំណងអប់រំតែប៉ុណ្ណោះ។ FNPNSW បានប្រកាន់យកនូវរាល់ការប្រុងប្រយ័ត្នដើម្បីធានាថាពត៌មានគឺមានភាពត្រឹមត្រូវនិងទាន់សម័យនៅឯពេលវេលានៃការបោះពុម្ពផ្សាយ។ បុគ្គលទាំងឡាយដែលមានការព្រួយបារម្ភអំពីការបន្តពូជផ្ទាល់ខ្លួន ឬ បញ្ហាសុខភាពរួមភេទ ត្រូវបានលើកទឹកចិត្តដើម្បីអោយស្វែងរកដំបូន្មាននិងជំនួយគាំទ្រពីអ្នកផ្តល់ការថែរក្សាសុខភាពរបស់ពួកគេ ឬទស្សនាគ្លីនិចផែនការគ្រួសារ។
ពិនិត្យសើរើឡើងវិញ: មិថុនា 2014/FPNSW 06/14

family planning nsw
Reproductive & Sexual Health

## តើអ្នកទទួលបានការគ្រៀវបំពង់ស្បូនមិនអោយមានកូនយ៉ាងដូចម្តេច?

ការគ្រៀវបំពង់ស្បូនមិនអោយមានកូនអាចត្រូវរៀបចំចាត់ចែងតាមរយៈវេជ្ជបណ្ឌិតនៅតាម មូលដ្ឋាន គ្រូពេទ្យជំនាញខាងរោគស្ត្រី ផ្នែកមន្ទីរពេទ្យគាំពារ ឬគ្លីនិចផែនការគ្រួសារ។ សំរាប់ ពត៌មានស្តីពី Essure® សូមមើលទៅ www.essure.com

## សំរាប់ពត៌មានថែមទៀត

- *ទាក់ទងផែនការគ្រួសារ NSW តាមខ្សែទូរស័ព្ទនិយាយលេខ 1300 658 886 ឬ មើល www.fpnsw.org.au/talkline*
- *NRS (សំរាប់អ្នកថ្លង់) 133 677*
- *ឬទស្សនាគ្លីនិចផែនការគ្រួសារដែលជិតបំផុតរបស់អ្នក*


ផែនការគ្រួសារ NSW គឺជាអង្គការមិនរកកម្រៃមួយដែលត្រូវបានផ្តល់មូលនិធិដោយក្រសួងសុខាភិបាល នៃរដ្ឋ NSW

ពត៌មាននៅក្នុងក្រដាសអង្គហេតុនេះត្រូវបានផ្តល់ជូនសំរាប់គោលបំណងអប់រំតែប៉ុណ្ណោះ។ FNPNSW បានប្រកាន់យកនូវរាល់ការប្រុងប្រយ័ត្នដើម្បីធានាថាពត៌មានគឺមានភាពត្រឹមត្រូវនិងទាន់សម័យនៅឯពេលវេលានៃការបោះពុម្ពផ្សាយ។ បុគ្គលទាំងឡាយដែលមានការព្រួយបារម្ភអំពីការបន្តពូជផ្ទាល់ខ្លួន ឬ បញ្ហាសុខភាពរូមភេទ ត្រូវបានលើកទឹកចិត្តដើម្បីអោយស្វែងរកដំបូន្មាននិងជំនួយគាំទ្រពីអ្នកផ្តល់ការថែរក្សាសុខភាពរបស់ពួកគេ ឬទស្សនាគ្លីនិចផែនការគ្រួសារ។
ពិនិត្យសើរើឡើងវិញ: មិថុនា 2014/FPNSW 06/14

Fact Sheet - English

# TUBAL STERILISATION

## What Is Tubal Sterilisation?

Tubal sterilisation is an operation that women can have so that they cannot become pregnant. It is a permanent form of contraception.

## How Does Tubal Sterilisation Work?

The operation blocks a woman's Fallopian tubes so that the sperm cannot travel up to meet the ovum (egg) and start a pregnancy.

## How Well Does It Work?

Tubal sterilisation works very well. It is more than 99% effective.

## What Happens When You Have A Tubal Sterilisation?

The most common method is called Laparoscopic Sterilisation. With this method women usually have a general anaesthetic, and stay overnight in hospital.

The doctor makes one or two small incisions in the abdomen. Then a laparoscope (a tiny telescope) is inserted so the doctor can see the tubes. The tubes are closed off with clips, rings, or by cutting and tying. A newer method is called Essure®. With this method small micro-inserts are placed in each Fallopian tube through the vagina and cervix.

TUBAL LIGATION




With Essure® there are no incisions and it can be done under a local anaesthetic. It takes about 30 minutes and most women can go home after about one hour.

## After A Tubal Sterilisation

After a general anaesthetic you may have nausea (sick feeling) or tiredness for a couple of days.

After laparoscopy, you may have some pain in your abdomen and shoulder. It usually takes about seven days for a woman to feel quite well again. Women who have the Essure® procedure with a local anaesthetic usually recover more quickly.

## When Will It Be Effective?

For laparoscopic methods you will be covered for contraception right away. The Essure® method usually takes three months to work, but it may take longer.

You should use another method of contraception until tests show that the tubes are fully blocked.

## Are There Any Side Effects?

With any operation, you can have complications such as bleeding and infection, but they are not common.

## What If It Doesn't Work?

About two to nine in 1,000 operations fail. It can happen even years later. If it fails there is more chance of a pregnancy being ectopic (outside the uterus).

## Can Tubal Sterilisation Be Reversed?

Sometimes laparoscopic sterilisation can be reversed, but even then only about 50% of women become pregnant. There is also a higher risk of ectopic pregnancy. The Essure® method cannot be reversed.

If a woman thinks there is any chance she may want a child in the future she should not have tubal sterilisation. It is best not to make such a big decision if you are under stress, such as just after having a baby, or a miscarriage, or when you have other problems.



Family Planning NSW is a not-for-profit organisation funded by the NSW Ministry of Health

The information in this Fact Sheet has been provided for educational purposes only. FNPNSW has taken every care to ensure that the information is accurate and up-to-date at the time of publication. Individuals concerned about any personal reproductive or sexual health issue are encouraged to seek advice and assistance from their health care provider or visit a Family Planning Clinic.

Reviewed May 2014/FPNSW 05/14

family planning nsw
Reproductive & Sexual Health

## How Do You Get A Tubal Sterilisation?

A tubal sterilisation can be arranged through a local doctor, a gynaecologist, a hospital outpatient department or Family Planning clinic. For information on Essure® go to www.essure.com

## For Further Information

- Contact the Family Planning NSW Talkline on 1300 658 886 or go to www.fpnsw.org.au/talkline
- NRS (for deaf) 133 677
- Or visit your nearest Family Planning clinic

*Reviewed: June 2014 | FPNSW 06/14*

*The information in this Factsheet has been provided for educational purposes only. Family Planning NSW has taken every care to ensure that the information is accurate and up-to-date at the time of publication. Individuals concerned about any personal reproductive or sexual health issue are encouraged to seek advice and assistance from their health care provider or visit an Family Planning NSW clinic.*